ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០៣១០.១៥.អឧធ.លាក

# សារាចរ
# ស្តីពី
# វិធានការចំពោះការដឹកជញ្ជូនរ៉ែសំណង់គ្រប់ប្រភេទ

ក្រសួងរ៉ែ និងថាមពលបានសង្កេតឃើញថា កន្លងមកការដឹកជញ្ជូនរ៉ែសំណង់គ្រប់ប្រភេទ មានជាអាទិ៍ថ្ម ក្រួស ខ្សាច់ ដីក្រហម ដីឥដ្ឋ អាចម៍ដី។ល។ដែលអាជីវករ ក្រុមហ៊ុនធ្វើអាជីវកម្មរ៉ែ បានដឹកជញ្ជូនចេញពីការដ្ឋានរ៉ែ ឆ្ពោះទៅកាន់គោលដៅនានាក្នុងបំណងពាណិជ្ជកម្មរបស់ខ្លួន បានបង្កឱ្យមានការប៉ះពាល់ដល់បរិស្ថានធ្ងន់ធ្ងរ ដោយការដឹកជញ្ជូនច្រើនហួសកំណត់ធ្វើឱ្យមានការជ្រុះធ្លាក់ថ្ម ក្រួស ខ្សាច់ ដីរាយប៉ាយនៅតាមដងផ្លូវ ធ្វើឱ្យមានការខូចខាតផ្លូវ និងប៉ះពាល់សុវត្ថិភាព សុខភាពរបស់ប្រជាពលរដ្ឋដែលរស់នៅតាមដងផ្លូវឬធ្វើដំណើរតាមបណ្តោយផ្លូវនោះ លើសពីនេះទៀត ការដឹកជញ្ជូនដោយមិនមានការទទួលខុសត្រូវបានបង្កឱ្យមានគ្រោះថ្នាក់ជារឿយៗ ដល់ជីវិតមនុស្ស សត្វ នៅលើផ្លូវដែលដឹកជញ្ជូននោះ ដោយសារធូលីហុយសំពោង និងការបើកបរដោយគ្មានការប្រុងប្រយ័ត្នជាដើម។

ផ្តើមចេញពីបញ្ហាខាងលើនេះ ក្រសួងរ៉ែ និងថាមពលសម្រេចដាក់ចេញនូវវិធានការចំពោះការដឹកជញ្ជូនរ៉ែសំណង់គ្រប់ប្រភេទដូចខាងក្រោមនេះ៖

១) អាជីវករ ក្រុមហ៊ុនរ៉ែទាំងអស់ត្រូវផ្ទុករ៉ែសំណង់លើរថយន្តដែលត្រូវដឹកជញ្ជូនរ៉ែចេញពីការដ្ឋាន ឬដេប៉ូរបស់ខ្លួនក្នុងកម្រិតមិនឱ្យហួសពីទ្រុងរថយន្តដែលត្រូវដឹកជញ្ជូននោះឡើយ។ការដឹកជញ្ជូនត្រូវគោរពតាមបទដ្ឋាននៃការកម្រិតទម្ងន់ផ្ទុកតាមប្រភេទរថយន្ត និងតាមប្រភេទផ្លូវដឹកជញ្ជូន។

២) ការដឹកជញ្ជូនរ៉ែសំណង់តាមរថយន្ត ត្រូវមានគម្របតង់កៅស៊ូគ្របពីលើឱ្យជិត ហើយចងឱ្យជាប់គត់មត់ ចៀសវាងការធ្លាក់នូវថ្ម ក្រួស ខ្សាច់ ដីក្រហម ដីឥដ្ឋ ឬអាចម៍ដី។ល។នៅតាមផ្លូវដែលដឹកជញ្ជូន។

៣) អាជីវករ ក្រុមហ៊ុនត្រូវចូលរួមក្នុងការថែរក្សាផ្លូវ ដែលខ្លួនបានប្រើប្រាស់ក្នុងការដឹកជញ្ជូនរ៉ែសំណង់ចេញពីការដ្ឋាន ឬពីដេប៉ូរបស់ខ្លួន ដោយត្រូវធ្វើការស្រោចទឹកជាប្រចាំ ដោយមិនបង្កឱ្យមានការរំខានដោយសារធូលីហុយ ធ្វើឱ្យមានការប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ឬអ្នកធ្វើដំណើរតាមដងផ្លូវនោះ។

៨) អាជីវករ ក្រុមហ៊ុន ត្រូវមានផែនការជួសជុលផ្លូវដែលចេញពីការដ្ឋានរបស់ខ្លួនឆ្ពោះមកផ្លូវខេត្ត ឬផ្លូវជាតិ។ ក្នុងករណីដែលផ្លូវនោះត្រូវបានប្រើប្រាស់ដោយអាជីវករ ក្រុមហ៊ុនលើសពីមួយ អាជីវករ ក្រុមហ៊ុនទាំងនោះត្រូវសហការគ្នាក្នុងការស្រោចទឹក និងថែទាំផ្លូវសម្រាប់ការប្រើប្រាស់ជាសាធារណៈ។

មន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត ត្រូវធ្វើការត្រួតពិនិត្យយ៉ាងម៉ឺងម៉ាត់បំផុតចំពោះការអនុវត្តវិធានការចំពោះការដឹកជញ្ជូនរ៉ែសំណង់ខាងលើនេះ។ ក្នុងករណីដែលអាជីវករ ក្រុមហ៊ុនប្រព្រឹត្តល្មើសចំណុចណាមួយនៃវិធានការខាងលើ មន្ទីររ៉ែ និងថាមពលត្រូវចាត់វិធានការផ្អាកការធ្វើអាជីវកម្មការដ្ឋាននោះចំនួន០១(មួយ)សប្តាហ៍ ដោយធ្វើការព្រមានជាលាយល័ក្ខអក្សរនិងបញ្ជាក់ពីចំណុចនៃការប្រព្រឹត្តល្មើសក្នុងលិខិតព្រមាននោះ។

ប្រសិនបើអាជីវករ ក្រុមហ៊ុន ប្រព្រឹត្តល្មើសនឹងវិធានការខាងលើនេះចំនួន០៣(បី)លើកក្នុងរយៈពេល១២(ដប់ពីរ)ខែ ការដ្ឋានអាជីវកម្មរ៉ែសំណង់នោះត្រូវបិទជាស្ថាពរ ហើយមន្ទីររ៉ែ និងថាមពលត្រូវរៀបចំសំណុំលិខិតដើម្បីដកហូតអាជ្ញាបណ្ណផនធានរ៉ែស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។ អាជីវករ ក្រុមហ៊ុនដែលទទួលរងនូវការដកហូតអាជ្ញាបណ្ណ ដោយកាប្រព្រឹត្តល្មើសនឹងវិធានការខាងលើនេះ នឹងត្រូវកត់ត្រាចូលបញ្ជីខ្មៅរបស់ក្រសួងរ៉ែ និងថាមពល ដោយមិនអនុញ្ញាតឱ្យចូលធ្វើអាជីវកម្មគ្រប់សកម្មភាពទាំងអស់ដែលពាក់ព័ន្ធនឹងវិស័យរ៉ែចំនួន០៣(បី)ឆ្នាំ។

ទទួលបានសារាចរនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង ត្រូវផ្សព្វផ្សាយ និងអនុវត្តឱ្យមានប្រសិទ្ធភាព ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយធ្វើរបាយការណ៍អំពីលទ្ធផលនៃការអនុវត្តជូនមកក្រសួងរ៉ែ និងថាមពលវិញ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែ តុលា ឆ្នាំ ២០១៥

រដ្ឋមន្ត្រី

ស៊ុយ_សែម

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងបរិស្ថាន
- សាលារាជធានី ខេត្ត
- មន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត"ដើម្បីផ្សព្វផ្សាយនិងអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ